# សំណង់ផ្សេងៗនៅក្នុងវត្ត (ភាគ២ បញ្ចប់)

ក្រៅពីសាទ្បុំ ឧបោសថាគារ ព្រះវិហារ សាលាឆាន់ និងកុដិតូចធំដូចខ្ញុំបានរៀបរាប់ត្រួសៗក្នុងអត្ថបទភាគ១[១] នៅក្នុងវត្តអារាម គេឃើញមានអគារផ្សេងៗទៀតកសាងឡើងប្រកបដោយលក្ខណៈស្ថាបត្យកម្ម និងគំនិតសិល្បៈទាំងបុរាណ និងទំនើប។ សំណង់ខ្លះគឺជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ការសិក្សារៀនសូត្ររបស់ព្រះសង្ឃដូចជា សាលាបាលី និងហោត្រ័យ។ សំណង់ខ្លះ ជានិមត្តរូបនៃព្រះពុទ្ធសាសនា ឬជំនឿរបស់អ្នកស្រុកដូចជា ចេតិយ ប្រាង្គ ឬស្តូប ហើយសំណង់ខ្លះកសាងឡើងសម្រាប់រៀបចំកិច្ចពិធីតាមទំនៀម និងជំនឿអ្នកស្រុកដូចជា ឈាបនដ្ឋាន ឬមេរុ ព្រមទាំងសំណង់ខ្លះទៀតកសាងឡើងតម្រូវតាមការចាំបាច់របស់វត្តដូចជា រោងទូក រោងបាយ តូបដូនជី-តាជី ។ល។

**ក.សាលាបាលី៖** គឺជាអគារសិក្សាចាំបាច់បំផុតនៅតាមវត្តរាម ដែលគេតែងហៅថា "ពុទ្ធិកសិក្សា"។ ជាទូទៅនៅក្នុងវត្តនីមួយៗ គេឃើញយ៉ាងហោចណាស់មានសាលាពុទ្ធិកបឋមសិក្សា សម្រាប់បើកបង្រៀនដល់ព្រះសង្ឃដែលបួសគង់នៅក្នុងវត្តនោះ។ នៅតាមតំបន់ខ្លះគេហៅសាលានេះថា "សាលាធម្មវិន័យ" ឬខ្លះហៅថា "សាលាធម្មត្រៃ"។[២] សំណង់ទាំងនេះអាចសង់ពីឈើ ឬថ្ម អាស្រ័យតាមការនិយម និងធនធាន ហើយនៅតាមវត្តទូទៅអាចមានពុទ្ធិកបឋមសិក្សា ពុទ្ធិកអនុវិទ្យាល័យ ឬពុទ្ធិកវិទ្យាល័យ អាស្រ័យតាមតម្រូវការរបស់ព្រះសង្ឃក្នុងវត្តសាមីុ និងវត្តជុំវិញ (រូបលេខ១-៣)។ ផុតពីកម្រិតនោះ ព្រះសង្ឃអាចនិមន្តសិក្សាបន្តនៅពុទ្ធិកសាកលវិទ្យាល័យស្ថិតនៅតាមទីរួមខេត្ត ឬនៅរាជធានីភ្នំពេញ។



*រូបលេខ១-៣ សាលាពុទ្ធិកសិក្សាវត្តសោមនស្ស (បាត់ដំបង), វត្តព្រះពន្លៃ និងវត្តវើល (ត្បូងឃ្មុំ)*

---

[១] សូមអាន "សំណង់ផ្សេងៗនៅក្នុងវត្ត (ភាគ១)" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/26125 ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

[២] ព្រាប ចាន់ម៉ារ៉ា ២០១៧: ៧៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# *អត្ថបទ៖ សំណង់ផ្សេងៗនៅក្នុងវត្ត (ភាគ២ បញ្ចប់)*

***ខ.ហោត្រ័យ៖*** *គឺជាអគារដ៏មានសារៈសំខាន់បំផុត សម្រាប់បម្រើឱ្យវិស័យសិក្សានៅតាមវត្តអារាម ទន្ទឹមនឹងសាលាពុទ្ធិកសិក្សា។ អ្នកខ្លះហៅសំណង់នេះថាបណ្ណាល័យ ឬខ្លះទៀតហៅថាធម្មមន្ទីរ ឬធម្មត្រ័យ ដែលទុកជាអគារសម្រាប់តម្កល់ឯកសារសំខាន់ៗផ្សេងៗដូជា គម្ពីរ ក្បួន ច្បាប់ សាស្ត្រា ហើយជាពិសេសគឺតម្កល់ព្រះត្រៃបិដកសម្រាប់ព្រះសង្ឃសិក្សារៀនសូត្រ។[៣] ជាទូទៅគេច្រើនសង់ហោត្រ័យនៅក្បែរនឹងសាលាពុទ្ធិកសិក្សា ហើយគេអាចសង់តាមទម្រង់សំណង់បុរាណ ឬទំនើបតាមការនិយម (រូបលេខ៤-៧)។ មិនតែប៉ុណ្ណោះនៅតាមវត្តខ្លះ គេតែងតម្កល់ទុករបស់មានតម្លៃជាសម្បត្តិរួមរបស់សហគមន៍នៅក្នុងហោត្រ័យដែរ។*



*រូបលេខ៤ ធម្មមន្ទីរវត្តត្នោតជុំ, សង់ឆ្នាំ១៩៣៣ (កំពង់ធំ)*



*រូបលេខ៥ ហោត្រ័យវត្តរកាឃ្លួច (ត្បូងឃ្មុំ)*



*រូបលេខ៦ ធម្មត្រ័យវត្តអង្គរខាងត្បូង (សៀមរាប)*



*រូបលេខ៧ ហោត្រ័យវត្តព្រះនាង (កំពង់ធំ)*

---

*[៣] សាន ផល្លា ២០០៧: ១០*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

***គ.ឈាបនដ្ឋាន ឬមេរុ៖*** *គឺជាកន្លែងសម្រាប់បូជាសព ដែលគេអាចកសាងនៅក្នុងបរិវេណវត្ត ឬទីទំនេរណាមួយក្នុងទិសឦសាន (រូបលេខ៨-១០)។ សំណង់នេះ ខ្លះហៅថា "ប៉ាឆា" ឬហៅរត់មាត់ថា "បច្ឆា" ក៏មាន។ ប៉ុន្តែបើគេសង់ក្នុងពិធីបូជាសពនៅតាមជនបទ ជាពិសេសនៅតំបន់អង្គរគេហៅថា "ភ្នំយោង" ហើយគេក៏តែងសង់រំកិលទៅទិសឦសាន នៃរោងបុណ្យដែរ ដ្បិតទិសនេះជាទិសពាក់ព័ន្ធនឹងជំនឿកើត និងស្លាប់។[៨] រីឯឈាបនដ្ឋាន ឬមេរុនៅតាមវត្ត គេសម្គាល់ឃើញធ្វើរាងជាមេរុមុខដាច់ ដែលមានដំបូលត្រួតគ្នា បែរទៅទិសទាំងបួន មានកំពូលស្រួចទៅលើ។ ចំពោះខ្លឹមសារនៃឈាបនដ្ឋានឬមេរុនេះ ក៏មានន័យដូចចេតិយដែរ ពោលគឺជាជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាស្ថានទេពស្ថានឬស្ថានខ្ពង់ខ្ពស់ ជាទីប្រាថ្នាឱ្យអ្នកស្លាប់បានទៅចាប់កំណើត។*



*រូបលេខ៨-១០ ឈាបនដ្ឋាន ឬមេរុវត្តកំពង់ត្រឡាចលើ (កំពង់ឆ្នាំង) វត្តចក និងវត្តដំណាក់ (សៀមរាប)*

***ឃ.ចេតិយ៖*** *តាមជំនឿគេយល់ថាចេតិយមានតួនាទីនិងនិមិត្តរូបដូចប្រាសាទដែរ គឺគេទុកដូចជាភ្នំព្រះសុមេរុដែលជាស្ថានទេពនៅកណ្តាលចក្រវាល ឬលោកធាតុ។ ធាតុអ្នកស្លាប់ដែលបញ្ចុះក្នុងចេតិយ គឺឧទ្ទិសឱ្យបានទៅដល់ "សុគតិភព" ជាទេវស្ថាន ឬទេវលោក។[៩] ក្នុងសិល្បៈពុទ្ធសាសនាគេយល់ថាចេតិយមាន៤ យ៉ាងគឺ ធាតុចេតិយ (ចេតិយសម្រាប់បញ្ចុះធាតុអ្នកស្លាប់) ធម្មចេតិយ (ចេតិយសម្រាប់តម្កល់គម្ពីរ ក្បួន ច្បាប់ វិន័យ...)*

---

[៨]*អាំង ជូលាន, ស៊ុន ចាន់ដឹប, ព្រាប ចាន់ម៉ារ៉ា ២០១៤: ៧៤ និងព្រាប ចាន់ម៉ារ៉ា ២០១៣: ៤-២០*

[៩]*ព្រាប ចាន់ម៉ារ៉ា ២០១៧: ៩១*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

បរិភោគចេតិយ (បញ្ចុះគ្រឿងបរិក្ខាររបស់ព្រះ ឬព្រះសង្ឃ) និងឧទ្ទេសិកចេតិយ (សម្រាប់គោរពបូជាដូចព្រះ ឬសម្រាប់ឧទ្ទិសទុកជាទីសក្ការៈ) (រូបលេខ១១-១៣)។[៦]



រូបលេខ១១ ព្រះសក្យមុនីចេតិយ វត្តបុទុម (កំពង់ធំ)



រូបលេខ១២ ព្រះសក្យមុនីចេតិយ វត្តមជ្ឈិមវ័ន (ភ្នំពេញ)



រូបលេខ១៣ ឧទ្ទេសិកចេតិយ វត្តត្នោតជុំ (កំពង់ធំ)

នៅតាមវត្តខ្លះ អ្នកស្រុកតែងមានទំនៀមសង់ចេតិយធំមួយទុកសម្រាប់តម្កល់ជាតុរួមៗ រីឯនៅតាមវត្តខ្លះទៀត គេតែងឃើញមានបណ្តុំចេតិយតូចធំ ប្រកបដោយក្បាច់រចនាសម្បូរបែបច្រើនយ៉ាងតាមទឹកដៃសិល្បៈស្រុកទេស (រូបលេខ១៤-១៦) ហើយលើចេតិយបុរាណខ្លះ តែងសង្កេតឃើញមានពាក្យឧទ្ទិសក្នុងន័យគោរពសក្ការៈ ឬ "សូមឱ្យព្រះពុទ្ធសាសនាបាន៥០០០ព្រះវស្សា"។ ប៉ុន្តែសព្វថ្ងៃ គេច្រើនសង់ចេតិយមានទម្រង់ដូចៗគ្នាជាជួរៗនៅជុំវិញព្រះវិហារ។







រូបលេខ១៤-១៦ ទម្រង់ផ្សេងៗនៃចេតិយនៅវត្តអង្គរខាងជើង (សៀមរាប) វត្តក្ដាំង៉ារ (បាត់ដំបង) និងវត្តសិលានទី (ក្រចេះ)

[៦] សូរ ហាយ ១៩៥៩: ១២១-១២៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

**ង.រោងទូក៖** នៅតាមបណ្តាវត្តនីមួយៗ ជាពិសេសវត្តតាមដងទន្លេ គេតែងសង្កេតឃើញសង់រោងទូកនៅក្បែរព្រះវិហារ (ភាគច្រើនទិសឦសាន) (រូបលេខ១៧-១៨)។ ប៉ុន្តែអ្នកស្រុកតំបន់ខ្លះ គេអាចយកទូកទៅតម្កល់ទុកក្រោមដើមឈើ ឬសង់រោងជាប់នឹងមាត់ទន្លេតែម្តង។[៧] ក្នុងរោងទូកនីមួយៗគេតែងមានដាក់ក្ងស់មួយខាងក្បាលទូកនិងរៀបគ្រឿងសក្ការៈថ្វាយរាល់ថ្ងៃសីល ឬក្នុងថ្ងៃបុណ្យផ្សេងៗ ដ្បិតគេយល់ថានៅជាប់នឹងក្បាលទូកតែងមានព្រាយចាំថែរក្សា (រូបលេខ១៩)។[៨] មិនតែប៉ុណ្ណោះ នៅក្បែររោងទូកក្នុងវត្តខ្លះតែងមានខ្ទមអ្នកតាតម្កល់បំណែកទូកបាក់បែកចាស់ៗ ដែលនាំឱ្យគេមើលឃើញច្បាស់ពីជំនឿយ៉ាងមុតមាំរបស់អ្នកស្រុកចំពោះការសង់រោងទូកនៅតាមវត្ត (រូបលេខ២០)។



រូបលេខ១៧ រោងទូកវត្តព្រះធាតុបាស្រី (ត្បូងឃ្មុំ)



រូបលេខ១៨ រោងទូកវត្តបុទុមវង្សី (កណ្តា



រូបលេខ១៩ ថ្វាយចេកក្បាលទូក
ក្នុងថ្ងៃបុណ្យវត្តស្វាយអណ្តែត (កណ្តាល)



រូបលេខ២០ បំណែកក្បាលទូកតម្កល់ក្នុងខ្ទមអ្នកតា
នៅវត្តល្វាលើ (សង្កាត់កោះដាច់, ភ្នំពេញ)

[៧] យ៉ា ដា ១៩៩៥: ៣១

[៨] Ang Chouléan 1986: 138-141

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

**ច.សំណង់ផ្សេងៗ៖** ក្រៅពីសំណង់សំខាន់ៗដូចរៀបរាប់ខាងលើ នៅតាមវត្តខ្លះគេឃើញមានសំណង់ផ្សេងៗទៀតកសាងតម្រូវតាមការចាំបាច់ក្នុងវត្ត តែពោរពេញដោយទឹកដៃសិល្បៈគួរឱ្យកោតសរសើរ។ រូបលេខ២១-២២ គឺជារោងសម្រាប់ព្រះសង្ឃចម្អិនចង្ក្រាន់(រោងបាយ)នៅវត្តកោះតូច និងវត្តព្រះប្រសប់។ ជាទូទៅគេសង់រោងនេះទាបជាប់ដីនៅក្បែរសាលាឆាន់ ហើយធ្វើឱ្យស្រឡះ និងមានខ្យល់ចេញចូលល្អ។ អ្វីគួរឱ្យកត់សម្គាល់រោងបែបនេះច្រើនធ្វើដំបូលតាមបែបផ្សេងៗ អាស្រ័យតាមចំណូលចិត្តអ្នកស្រុក។




*រូបលេខ២១-២២ រោងចម្អិនចង្ក្រាន់ព្រះសង្ឃនៅវត្តកោះតូច និងវត្តព្រះប្រសប់ (កណ្ដាល)*

រូបលេខ២៣ ជាតូបដូនជីនៅវត្តបុទុម ក្នុងខេត្តកំពង់ធំ។ ជាទូទៅ គេច្រើនសង់តូបសម្រាប់ដូនជីស្នាក់នៅមើលថែវត្ត ឬសម្រាប់ដូនជី-តាជី អញ្ជើញមកស្នាក់អាស្រ័យរក្សាសីលរាល់ខែ ឬពេលមានបុណ្យទាន។ ចំណែកឯរូបលេខ២៥-២៦ គឺជាជង្រុកស្រូវនៅវត្តស្ទឹង ខេត្តបាត់ដំបង និងជង្រុកស្រូវនៅវត្តសាមគ្គីរតនារាម នៅខេត្តតាកែវ។ មកដល់ត្រង់នេះសូមបញ្ជាក់ថា ដើមឡើយវត្តនៅតាមជនបទភាគច្រើនតែងមានស្រែជុំវិញវត្ត ហើយរាល់ខែមាឃគេច្រើនធ្វើបុណ្យដារលានពូនភ្នំស្រូវប្រគេនព្រះសង្ឃ។ នៅតាមវត្តខ្លះ តែងបរិច្ចាគស្រូវមួយភាគទៅដល់អ្នកក្រខ្សត់ផងក៏មាន។





*រូបលេខ២៣ តូបដូនជី* *រូបលេខ២៤-២៥ ជង្រុកស្រូវនៅវត្តស្ទឹង និងវត្តសាមគ្គីរតនារាម*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ សំណង់ផ្សេងៗនៅក្នុងវត្ត (ភាគ២ បញ្ចប់)

រូបលេខ២៦-២៧ គឺជាអគារសម្រាប់ហាត់រៀន និងសម្តែងសិល្បៈនៅវត្តប្រម៉ា ស្ថិតក្នុងខេត្តសៀមរាប។ សំណង់បែបនេះ គេច្រើនសង់នៅដីវត្តដែលទំនេរ តែឃ្លាតពីវត្តបន្តិច ដើម្បីងាយស្រួលសម្រាប់ហាត់រៀនសិល្បៈផ្សេងៗដូចជា ភ្លេង របាំ ឬល្ខោនជាដើម។ សូមកុំភ្លេចថា មកដល់សព្វថ្ងៃមានសិល្បៈបុរាណតាមសហគមន៍មួយចំនួនបានរស់រានឡើងវិញដោយការយកចិត្តទុកដាក់ពីសំណាក់វត្តអារាមដូចជា ស្បែកធំវត្តរាជបូព៌ (សៀមរាប) និងយីកេភូមិនីពេជ្រ (កំពង់ធំ) ជាដើម។



*រូបលេខ២៦-២៧ រោងសិល្បៈនៅវត្តប្រម៉ា (សៀមរាប)*

សរុបសេចក្តីមក សំណង់នៅតាមវត្តមានច្រើនបែបយ៉ាងណាស់ ហើយមានតួនាទីផ្សេងៗគ្នា។ សំណង់ខ្លះ គឺជាកន្លែងសក្ការៈសម្រាប់រៀបចំធ្វើបុណ្យទាន មានកំណត់គោលសីមា កំណត់ជាកន្លែងពិសិដ្ឋ។ សំណង់ខ្លះសម្រាប់បម្រើកិច្ចការទូទៅក្នុងពុទ្ធសាសនា និងក្នុងសហគមន៍។ សំណង់ខ្លះ កសាងឡើងទុកជាកន្លែងគង់នៅ ឬស្នាក់អាស្រ័យសិក្សារៀនសូត្ររបស់ព្រះសង្ឃ ដូនជី តាជី ឬកូនអ្នកស្រុកដែលចេញទៅបន្តការរៀនសូត្រឆ្ងាយពីគ្រួសារជាដើម។ លើសពីនេះ សំណង់ខ្លះទៀតមានតួនាទីជាផ្នែកយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងទ្រទ្រង់មត៌កវប្បធម៌។ ដូច្នេះសំណង់នីមួយៗនៅតាមវត្ត ក្រៅពីបង្ហាញពីទម្រង់ស្ថាបត្យកម្មបុរាណ ឬទំនើប វាក៏បង្ហាញឱ្យឃើញពីតួនាទី និងទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសហគមន៍ និងវត្តអារាមដែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៣, *ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

២០១៧, *ទម្រង់សំណង់ប្រពៃណីខ្មែរ សំណង់នៅតាមវត្ត*, ភាគ១, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

យ៉ា ដា

១៩៩៥, *ទូកប្រណាំងខ្មែរ*, សារណាបញ្ចប់បរិញ្ញាបត្រ មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រៃឃំ, ភ្នំពេញ

សូរ ហាយ

១៩៥៩, *ពុទ្ធសាសនា២៥០០*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អាំង ជូលាន, ស៊ុន ចាន់ដឹប, ព្រាប ចាន់ម៉ារ៉ា

២០១៨, *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, យសោធរ, ភ្នំពេញ

Ang Chouléan

1986, Les êtres surnaturels dans la religion populaire khmère, Cedoreck, Paris

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត